ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចព្រមព្រៀង
# រវាង
# សហជីពកម្មករនិយោជិតសណ្ឋាគាររ៉ាហ្វិលហ្គ្រែនឌឺអង្គរ
# និង
# ក្រុមហ៊ុនសណ្ឋាគាររ៉ាហ្វិលហ្គ្រែនឌឺអង្គរ

កិច្ចព្រមព្រៀងនេះត្រូវបានធ្វើឡើងនៅថ្ងៃ ទី២២ ខែមិថុនា ឆ្នាំ២០២០ រវាងសហជីពកម្មករ និយោជិតសណ្ឋាគាររ៉ាហ្វិលហ្គ្រែនឌឺអង្គរ (ពីនេះតទៅហៅថា"សហជីព") និង ក្រុមហ៊ុនសណ្ឋាគាររ៉ាហ្វិលហ្គ្រែនឌឺអង្គរ (ពីនេះតទៅហៅថា "និយោជក")។ ភាគីនីមួយៗអាចហៅដោយឡែកថា "ភាគី" និងហៅជារួមថា "គូភាគី"។

សណ្ឋាគារ Raffles Grand Hotel d'Angkor កំពុងប្រឈមនឹងការលំបាកផ្នែកសេដ្ឋកិច្ចក្នុងកំឡុងពេលនៃជំងឺរាតត្បាតជាសកល COVID-19 ដែលមិនធ្លាប់មានពីមុនមក។ ការផ្ទុះឡើងនៃជំងឺកូវីដណាវីរុស ទូទាំងពិភពលោកបានបណ្តាលឱ្យសណ្ឋាគារត្រូវបង្ខំចិត្តផ្អាកប្រតិបត្តិការរបស់ខ្លួន។ ដូច្នេះ និយោជក និងសហជីពបានធ្វើការចរចា និងព្រមព្រៀង លើការព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន ១៩១នាក់ (ស្រី ៧៣នាក់) ក្នុងចំណោមកម្មករនិយោជិតសរុបចំនួន ២១២នាក់ (ស្រី ៧៨នាក់) រយៈពេល ២៨ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី៤ ខែសីហា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២០។

គូភាគីទាំងពីរព្រមព្រៀងគ្នាទទួលយកលក្ខខណ្ឌដូចខាងក្រោម៖

និយោជិតដែលត្រូវបានព្យួរការងារជាបណ្តោះអាសន្ននឹងទទួលបានអត្ថប្រយោជន៍ដូចខាងក្រោម៖

- និយោជិតនឹងទទួលបានប្រាក់ឈ្នួល ៥០% នៃប្រាក់ឈ្នួលគោលប្រចាំខែ ក្នុងអំឡុងពេលនៃការព្យួរការងារ។
- និយោជិតនឹងទទួលបាន**អង្ករ ១០ គីឡូក្រាម** [ស្មើ ៧.៥ ដុល្លារអាមេរិក] ជារៀងរាល់ខែ។
- រាល់អត្ថប្រយោជន៍ដែលមានស្រាប់ ដូចជាការធានារ៉ាប់រងផ្នែកវេជ្ជសាស្ត្រ នឹងបន្តក្នុងកំឡុងការព្យួរការងារ។
- អតីតភាពការងារនឹងមិនទទួលរងផលប៉ះពាល់។
- និយោជិតនឹងយកការឈប់សម្រាកប្រចាំឆ្នាំ និងថ្ងៃឈប់សំរាកបុណ្យជាតិដែលនៅសល់ រួមទាំងថ្ងៃឈប់សម្រាកបុណ្យចូលឆ្នាំខ្មែរ ឆ្នាំ២០២០ មុនពេលចាប់ផ្តើមអនុវត្តន៍គម្រោងព្យួរការងារ។

សណ្ឋាគារនឹងតម្រូវឱ្យនិយោជិតមួយចំនួនបន្តធ្វើការពេញម៉ោងក្នុងអំឡុងពេលនៃការផ្អាកប្រតិបត្តិការនេះ ដើម្បីថែទាំសណ្ឋាគារ។

- និយោជិតទាំងនេះនឹងទទួលបានប្រាក់ឈ្នួល ១០០%។
- និយោជិតដែលបំពេញការងារក្នុងអំឡុងពេលផ្អាកប្រតិបត្តិការសណ្ឋាគារនឹងទទួលបានប្រាក់ឧបត្ថម្ភធ្វើដំណើរបន្ថែមចំនួន **៣០ ដុល្លារ** ក្នុងមួយខែ។
- រាល់អត្ថប្រយោជន៍ដែលមានស្រាប់ ដូចជាការធានារ៉ាប់រងផ្នែកវេជ្ជសាស្ត្រនឹងនៅតែមានជាធម្មតា។
- និយោជិតដែលបំពេញភារកិច្ចនឹងទទួលបានអាហារជាធម្មតា។
- និយោជិតទាំងនេះអាចនឹងត្រូវបានស្នើសុំឱ្យបំពេញការងារក្រៅភារកិច្ចធម្មតារបស់ខ្លួន។ ប៉ុន្តែ ការបណ្តុះបណ្តាលដែលសមរម្យនឹងត្រូវបានផ្តល់ដើម្បីធានាថាកិច្ចការអាចត្រូវបានបញ្ចប់ដោយសុវត្ថិភាព (ឧទាហរណ៍៖ បុគ្គលិកផ្នែកម្ហូបអាហារនិងភេសជ្ជៈធ្វើការសំអាតអាងទឹក)។ ក្នុងករណីមានការកក់សណ្ឋាគារជាក្រុមភ្លាមៗក្នុងកំឡុងពេលផ្អាក

ប្រតិបត្តិការ និយោជិតមួយចំនួនឬទាំងអស់ អាចត្រូវបានគេតម្រូវឱ្យមកធ្វើការ។ និយោជិតនឹងទទួលបាន ប្រាក់ឈ្នួល ១០០%នៃប្រាក់ឈ្នួលប្រចាំថ្ងៃធម្មតារបស់ពួកគេ (ដោយមិនមានប្រាក់ឧបត្ថម្ភសំរាប់ការធ្វើដំណើរ) ខណៈប្រាក់ធានានុគ្រោះត្រូវបានផ្តល់ជូនសំរាប់និយោជិកដែលបានបំពេញភារកិច្ច។

នៅពេលស្ថានភាពជំងឺ Covid-19 មានភាពប្រសើរឡើងវិញ និយោជកនឹងមានកាតព្វកិច្ចទាក់ទងនិយោជិតគ្រប់ៗគ្នាដើម្បីវិលត្រឡប់មកធ្វើការងារដូចធម្មតាវិញ ហើយអត្ថប្រយោជន៍ដែលមាននៅក្នុងកិច្ចព្រមព្រៀងអនុសញ្ញារួមនឹងត្រូវរក្សានៅដដែល។

គូភាគីព្រមព្រៀងលើកិច្ចព្រមព្រៀងនេះដោយចុះហត្ថលេខាខាងក្រោមនេះ៖

ចុះហត្ថលេខាតាងនាមភាគីនិយោជក

សៀមរាប ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២០

ហត្ថលេខា និងត្រា

នាយកសណ្ឋាគារ

Oliver Dudler

ចុះហត្ថលេខាតាងនាមភាគីសហជីព

រស់ ប៊ុនណាល់

ប្រធានសហជីព

22/06/20

វើង ភីរុធ

អនុប្រធានសហជីព

មៅ វណ្ណដា

លេខាធិការសហជីព